ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ៤

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



**Work Activities**

ប្រចាំខែមេសា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់សម្រាក គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា សកម្មភាពជនពិការ | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមីនា ឆ្នាំ២០១៣ | ៤ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# របបស្តីពីការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី០៤ ទី០៨ និងទី០៩ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ុខ ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ឡាំ ជា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីរបបស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរដ្ឋលេខាធិការមុខងារសាធារណៈ។



រដ្ឋលេខាធិការមុខងារសាធារណៈ បានតាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរបបសុំច្បាប់ឈប់សម្រាករបស់មន្ត្រីរាជការស៊ីវិល និងបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសម្តងរួចហើយ។ ពេលនោះអង្គប្រជុំជំនាញបច្ចេទេសបានស្នើឲ្យមានការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាសិន ទើបអាចដំណើរការសេចក្តីព្រាងអនុក្រឹត្យនេះតទៅមុខទៀតបាន។ ឥឡូវនេះ ច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា ១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលដាក់ឆ្លង ការពិនិត្យនិងអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា និងត្រូវប្រកាសឲ្យប្រើជាការប្រញាប់។ បន្ទាប់ពីនេះមក រដ្ឋលេខាធិការមុខងារសាធារណៈ បានស្នើដាក់សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ឆ្លងកិច្ចប្រជុំនានាតាមនីតិវិធីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ

កាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា**សកម្មភាពជនពិការ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា វិស័យពិការភាពមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ និងទទួលបានសមិទ្ធផលធំធេងជាបន្តបន្ទាប់។ ស្ថានភាពរបស់ជនពិការកម្ពុជាមានភាពល្អប្រសើរឡើងជាលំដាប់។ គោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យពិការភាពត្រូវបានដាក់ឲ្យអនុវត្តប្រកបដោយផ្លែផ្កា។ មជ្ឈដ្ឋានជាតិនិងអន្តរជាតិ និងបងប្អូនជនពិការមានការសប្បាយរីករាយ គាំទ្រចំពោះការគិតគូរ និងយកចិត្តទុកដាក់ខ្ពស់របស់ សម្តេចតេជោ ប្រមុខរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធកាកបាទក្រហមកម្ពុជា និងអង្គការដៃគូនានាចំពោះសុខុមាលភាពជនពិការ។ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣ កន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការជាផ្លូវការ ដែលនេះជាសមិទ្ធផលថ្មីមួយទៀតនៃវិស័យពិការភាពនៅកម្ពុជា និងជាការលើកទឹកចិត្តបន្ថែមទៀតដល់បងប្អូនជនពិការ។ ដើម្បីបំពេញកាតព្វកិច្ចជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ បានសហការជាមួយគណៈកម្មាធិការអង្គការសហប្រជា-



ជាតិផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច សម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក រៀបចំពិធីប្រកាសជាផ្លូវការនូវការប្តេជ្ញាចិត្តអនុវត្តសញ្ញាស្តីពីសិទ្ធិជនពិការ យុទ្ធសាស្ត្រអ៊ីនឈាន់ឆ្នាំ២០១២-២០២២ និងការប្រកាសស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីជនពិការឆ្នាំ២០១៤-២០១៨ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលក្នុងពិធីនោះ សម្តេចតេជោ នាយករដ្ឋមន្ត្រី នឹងប្រគល់ភារកិច្ចអនុវត្តគោលការណ៍ខាងលើនេះ ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ។ ដើម្បីអនុវត្តកាតព្វកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ដោយបានកែសម្រួលអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការរៀបចំសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការបន្ថែមសមាសភាព និងភារកិច្ចមួយចំនួនឲ្យស្របតម្រូវការបច្ចុប្បន្ន(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីពាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាសកម្មភាពជនពិការ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនា ឆ្នាំ២០១៣



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនា ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមីនា ឆ្នាំ២០១៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ0,១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១% ធៀបនឹងខែដូចគ្នាឆ្នាំមុន(ខែ១២រយៈពេល)។ ការថយចុះថ្លៃទំនិញប្រើប្រាស់ធៀបនឹងខែមុននេះ ជារួមបណ្តាលមកពីក្រុមការដឹកជញ្ជូន ដែលក្នុងនោះ មានការចុះថ្លៃប្រេងសាំង និងម៉ាស៊ូត។

**បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម**

| ក្រុមទំនិញ៖ | មុខទំនិញ៖ | |
|---|---|---|
| ម្ហូបអាហារ : +១,៧% | អង្ករ : +១,៧% | ឧស្ម័ន: -៦,១% |
| សម្លៀកបំពាក់ និងស្បែកជើង : +៣,២% | សាច់គោស្រស់: +១៦% | ប្រេងសាំង: -៣,៩% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន : -0,៣% | សាច់មាន់ស្រស់: +១,៩% | ប្រេងម៉ាស៊ូត: -៣,៩%។ |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ : +១,៧% | ត្រីស្រស់ : +១,២% | |
| ការដឹកជញ្ជូន: -២,៩% | បន្លែ: +៦,១% | |
| ភោជនីយដ្ឋាន: +៣,៧% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១បម្រែបម្រួល.សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១–២០១៣

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា[P] | ឧសភា[P] | មិថុនា[P] | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១៨%, | ១,៧% | ១,០% | *១,២%* | *១,៤%* | *១,៥%* | | | | | | | - |
| | ខែមុន | ០៣,% | ០,២% | ០-,១% | *០,៧%* | *-០,៩%* | *០,២%* | | | | | | | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥៨%, | ៥៤%, | ៥៤%, | ៤៨%, | ២២%, | ១៨%, | ១៣%, | ២,២% | ១,៤% | ១,២% | ១,៦% | ២៦%, | ២៩%, |
| | ខែមុន | ១០,% | ០៤,% | ០៦%, | ០៥%, | -១១%, | ០១%, | ០ | ១,១% | ០,២% | ០-,២% | ០-,២% | ០ | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦៥%, | ៧១%, | ៧១%, | ៦៤%, | ៦៧%, | ៥៣%, | ៥៦%, | ៤៩%, | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១៤%, | ០៥%, | ០៦%, | ០២%, | ១០%, | ០១%, | ០,៧%- | ០,៨%- | |

P: តួលេខខែ **មេសា ឧសភា និងមិថុនា** ឆ្នាំ២០១៣ ជាតួលេខព្យាករដោយ ក តាមវិធីសាស្រ្ត) .វ.ស.DECOMPOSITION)

ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១២ និង២០១៣ ធៀប) (នឹងខែដូចគ្នាឆ្នាំមុន។




➡អត្រាប្តូរប្រាក់៖

| *ប្រភេទ* | អត្រាខែមិនា ២០១៣ | អត្រាខែកុម្ភៈ ២០១៣ | អត្រាខែមិនា ២០១២ | *ប្រភេទ* | អត្រាខែមិនា ២០១៣ | អត្រាខែកុម្ភៈ ២០១៣ | អត្រាខែមិនា ២០១២ |
|---|---|---|---|---|---|---|---|
| រដុល្លា/ | ៣៩៩៥រ១/$ | ៣៩៩៥រ១/$ | ៣៩៩៥រ១/$ | បាតរដុល្លា/ | ២៩,៣២បាត/១$ | ២៩,៨៣បាត/១$ | ៣០,៨៧បាត/១$ |
| របាត/ | ១៣៦របាត១/ | ១៣៤របាត១/ | ១២៩របាត១/ | ដុងដុល្លារ/ | ២០៩២០ដុង១/$ | ២០៨៩០ដុង១/$ | ២០៨០០ដុង១/$ |
| រដុង/ | ០,១៩១រដុង១/ | ០,១៩១រដុង១/ | ០,១៩២រដុង១/ | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែមីនាឆ្នាំ ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ៖** អនុវត្តបាន ៦៧០៥, ពាន់លានរៀលមធ្យម)ប្រចាំខែ ៦១នៃ %គម្រោង( ក្នុងនោះចំណូលចរន្ត ៦៧០,៣ ពាន់លានរៀល មធ្យម)ប្រចាំខែ ៨៦% នៃគម្រោង( និងចំណូលមូលធន ០,៣ ពាន់លានរៀល។

- បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ** កើនឡើង៧% និងកើនឡើង៩% *ធៀបនឹងខែដូចគ្នាឆ្នាំមុន* ។ ក្នុងនោះ ចំណូលចរន្តកើនឡើង៨% ធៀបនឹងខែមុន និងកើនឡើង២០% *ធៀបនឹងខែដូចគ្នាឆ្នាំមុន*។
- នៅក្នុងចំណូលចរន្ត៖

ក្រាហ្វ ២២០១ ចំណូលថវិកាជាតិ ឆ្នាំ .២ និង ២០១៣
(ពាន់លានរៀល)



✓ ចំណូលសារពើពន្ធមានចំនួន ៥៨៨,៥ ពាន់លានរៀល កើនឡើង ១៥% ធៀបនឹងខែមុន និងកើនឡើង ១៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៨១,៨ ពាន់លានរៀល ថយចុះ ២៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ )ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន( | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ )ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន( | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : +១៩% | )+១២%( | ➢ នេសាទ: -៥៦% | )-៣៦%( |
| ➢ ចំណូលពន្ធដារ : +១០% | )+១៦%( | ➢ រុក្ខាប្រមាញ់ : — | )—( |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: -១៥% | )-៣២%( | ➢ អាកាសចរណ៍ស៊ីវិល : កើនយ៉ាងគំហុត | ) +៥៤១%( |
| ✧ កាស៊ីណូ : -៣៩% | )-៣៧%( | ➢ ផលទុនទេសចរណ៍ : +៣៨១% | កើនយ៉ាងគំហុត |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -១៩% | ) -៩៥%( | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : -៩៧% | )-៩៥%( |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ: +៨% | )-១៥%( | ➢ អាករស្ថានទូត លិខិតឆ្លងដែន) និងទិដ្ឋាការ(: កើនយ៉ាងគំហុត | (-២៦%) |

២.២. *ចំណាយថវិកាជាតិ៖* អនុវត្តបានចំនួន ៦៣០ពាន់លានរៀល )*មធ្យមប្រចាំខែ ៣៧* (*នៃគម្រោង* %ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៥១១ ពាន់លានរៀល )*មធ្យមប្រចាំខែ ៥១*និង (*នៃគម្រោង* %**ចំណាយមូលធន**ចំនួន ១១៩ ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ១២០ % និងកើនឡើង ១ % ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តកើនឡើង ១២៤% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៨ % ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ថវិកាជាតិនៃខែមិនាមានអតិរេក ៤១ ពាន់លានរៀល ស្មើនឹង ១០,២៥ លានដុល្លារ ស.រ.អា* ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមីនា ឆ្នាំ២០១៣ មានលក្ខណៈដូចខាងក្រោម៖

➢ រូបិយវត្ថុ $M_2$ មានចំនួន ៣០៤៨១ ពាន់លានរៀល កើនឡើង ២,២% ធៀបនឹងខែមុន និងកើនឡើង ២៣ % ធៀបនឹងខែដូចគ្នាឆ្នាំមុន។ កំណើន $M_2$ ធៀបនឹងខែមុន បណ្តាលមកពីរូបិយវត្ថុក្រៅធនាគារកើនឡើង ៣,១% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ២,៦%។

➢ ក្នុងខែនេះ ប្រាក់រៀលសរុប**នៅក្នុងនិងក្រៅធនាគារ** មានចំនួន ១៧ %នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨៣%។

ក្រាហ្វ៣២០១៣សមាសធាតុរូបិយវត្ថុខែមិនា ឆ្នាំ .



| សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ១៧,២% | ១៧,៣% | ១៧,០% | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣៧%, | ១៣៧%, | ១៣,៩% | | | | | | | | | |

## បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែមីនា២០១៣ :ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣៨២៤ លានដុល្លារ កើនឡើង ១,៣ %ធៀបនឹងខែមុន និង កើនឡើង ២០ %ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១០០៨៣ ពាន់លានរៀល កើនឡើង ២,៨% ធៀបនឹងខែមុន និងកើនឡើង ២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- *ការផ្តល់ឥណទាន៖*

| ផ្តល់ដោយ | មីនា ២០១៣ | កុម្ភៈ ២០១៣ | មីនា ២០១២ |
|---|---|---|---|
| ធនាគារពាណិជ្ជ (ពាន់លានរៀល) | ២៤៨០០ | ២៤១៧៥ | ១៨៧៧៣ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | មិនទាន់មានតួលេខ | ៣៧៩៣ | ២៨១៥ |

- ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែមីនា៖

| ប្រភេទអត្រាការប្រាក់ | មិនា ២០១៣ | កុម្ភៈ ២០១៣ | មិនា ២០១២ |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៩៣% | ៦,០២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៧៦% | ១៧,៦៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,៤៤% | ៤,៤៣% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៧១% | ១៣,៧៤% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមិនាឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ ផលិតផលនេសាទមានចំនួន៤២,០ ពាន់តោន ថយចុះ ១០% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**➢ឧស្សាហកម្មៈ**

- ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣១១,២ GWh កើនឡើង១១% ធៀបនឹងខែមុន និង កើនឡើង ២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ⇨ ក្នុងនោះវារីអគ្គិសនីមានចំនួន ៩៨, GWh កើនឡើង២% ធៀបនឹងខែមុន និងកើនឡើង ៧៦៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤២៣ លានដុល្លារ កើនឡើង៨% ធៀបនឹងខែមុន និងកើនឡើង ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្មៈ

| ប្រភេទ | ចំនួន— មីនា ២០១៣ | ចំនួន—កុម្ភៈ ២០១៣ | ចំនួន—មីនា ២០១២ |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ១០ | ១១ | ១៧ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ៩៤៤ | ៩៣៤ | ៧៣២ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៣ | ២៦ | ១៨ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១២ | ៩ | ២ |

**↳សំណង់ (ការអនុញ្ញាត)ៈ**

- ✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣២៦ ពាន់ម៉ $^{២}$ ថយចុះ ២៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៥៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ៩១ លានដុល្លារ ថយចុះ ២២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៥០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមានៈ

| ប្រភេទ | ពាន់ម៉ $^{២}$ —មិនា ២០១៣ | ពាន់ម៉ $^{២}$ —កុម្ភៈ២០១៣ | ពាន់ម៉ $^{២}$ —មិនា ២០១២ |
|---|---|---|---|
| ▪ លំនៅឋាន | ២០៤,៦ | ១០៥,៤ | ១២៥,១ |
| ▪ ឧស្សាហកម្ម | ៣៥,៨ | ១៧៩,០ | ៤៣,៨ |
| ▪ ពាណិជ្ជកម្ម | ៦១,២ | ៨,៤ | ១០,៨ |
| … | | | |
| អនុញ្ញាតសរុប | ៣២៦ | ៤៥២ | ២១០ |

- ✓ ដូច្នេះសំណង់ដែលពេញនិយមនាខែនេះគឺ លំនៅឋាន ៦៣នៃផ្ទៃ %ក្រឡាអនុញ្ញាតសរុប ឧស្សាហកម្ម ១១១៩ និងពាណិជ្ជកម្ម %%។

**↳ការងារៈ**

| ប្រភេទ | នាក់—មីនា២០១៣ | %∆ ធៀបនឹងខែមុន | %∆ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១២៤៩ | ២៩%- | ២១%- |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៩៤១ | ១២%+ | ៧%+ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៨២៦ | ៦២%+ | ១៧%+ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១១១៥ | ២៦%- | -៧% |

**វិនិយោគ៖**

✓ គម្រោងវិនិយោគអនុញ្ញាតដោយ គ(ថ្មីនិងពង្រីក) .ក.អ.ក/.ក.វ.៖

| ប្រភេទ | មីនា២០១៣ | កុម្ភៈ២០១៣ | មីនា២០១២ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២០ | ១២២ | ២៥៦ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ១៩ | ១៣១ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ២០ (០) | ៨២ (០) | ៧៤ (២៧) |
| វិស័យទេសចរណ៍ | ០ | ០ | ៥១ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ២១ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៥ | ១៩ | ២៥ |
| បង្កើតការងារ (ពាន់នាក់) | ៨ | ២៧ | ៣១ |

**សេវាកម្ម និងទេសចរណ៍៖**

✓ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន—មីនា២០១៣ | ចំនួន— កុម្ភៈ២០១៣ | ចំនួន—មីនា២០១២ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៣២ | ២២១ | ៣៣៤ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ០ | ០ | ៣ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៩៣ | ៩០ | ២០៣ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (កំពង់ផែ៥ សរុប) មានចំនួន ៥៤២ ពាន់តោន កើនឡើង ១០% ធៀបនឹងខែមុន និងកើនឡើង ១៦ %ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | |
|---|---|
| ▪ កំពង់ផែភ្នំពេញ: +១៨% )០ ( | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +១១% )+៧៦% ( |
| ▪ កំពង់ផែកំពង់សោម: +១០% )+១៨%( | ▪ កំពង់ផែឧកញ៉ាម៉ុង: -១០% ១-)%( |

**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន)ពាន់នាក់( | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១១ | -១៤% | -១៤% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | មិនទាន់មានតួលេខ | — | — |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | មិនទាន់មានតួលេខ | — | — |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៥ | -១% | +១២% |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ៣៨១ | -១% | +១៨% |
| ✓ តាមផ្លូវអាកាស | ១៩២ | -៦% | +២០% |
| ✓ តាមផ្លូវគោក និងទឹក | ១៩០ | +៤% | +១៦% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលនាខែមិនាមានចំនួន ២៧១៦ ពាន់លានរៀល (ស្មើនឹង ៦៧៩ លានដុល្លារ ស.អា.រ.) ថយចុះ ៣ %ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៧ %ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %∆ ធៀបនឹងខែមុន | %∆ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ ធៀបនឹងខែមុន | %∆ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៧% | +១២% | រថយន្តសរុប (រ.ល.ព) | +៦% | +២% |
| ប្រេងម៉ាស៊ូត | -៦% | ៧%- | រថយន្តសរុប (គ្រឿង) | +១៣% | ៦%- |
| ឧស្ម័ន | +៤៦% | +៤៨% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -២០% | +៦៨% |
| អគ្គិសនីនាំចូល | +១៣% | +២៨% | ម៉ូតូ (គ្រឿង) | +១៩% | ១៤%- |
| ដែកសំណង់ | +១៦១% | +១០៩% | អង្ករ | +១០៩% | +២៨០៨% |
| ស៊ីម៉ង់ត៍ | +៤៥% | +៣៦% | ផ្លែឈើ និងបន្លែ | +៣% | +១៧% |
| គ្រឿងអេឡិចត្រូនិក | +៣៥% | ៥%- | ជី និងថ្នាំកសិកម្ម | +៩៥% | +៨៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៣០% | +១៤% |

➡ **ការនាំចេញ** ក្នុងខែមីនាឆ្នាំ២០១៣ មានចំនួន ២២៥៨ ពាន់លានរៀល ស្មើនឹង ៥៦៤ លានដុល្លារ ស .អា.រ. នៃការ ៨៣%)នាំចូល( កើនឡើង ៣១ %ធៀបនឹងខែមុន និងកើនឡើង ២៨ % ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %∆ ធៀបនឹង ខែមុន | %∆ ធៀបនឹងខែ ដូចគ្នាឆ្នាំមុន | ទំនិញ | %∆ ធៀបនឹងខែមុន | %∆ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១០៤៥០% | +៨១៦% | ផលិតផលនេសាទ | +៤៤% | +៧៩% |
| វាយនភណ្ឌនិងស្បែកជើង | +២៤% | +១១% | កៅស៊ូ | ៥១%- | -៣២% |
| អង្ករ | +៤៤% | +១៧០% | | | |

➡ ក្នុងខែមីនានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៤៥៩ ពាន់លានរៀល ស្មើនឹង ១១៥ លានដុល្លារ ស.អា.រ.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមីនា ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| លរ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +១,១% | +១៦% | បញ្ហាការផ្គត់ផ្គង់ |
| ២ | ចំណូលពីកាស៊ីណូ | -៣៩% | -៣៧% | — |
| | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | -១៩% | -៩៥% | — |
| ៣ | ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ | -៨,២% | -២៥% | ជាចំនួនប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ |
| ៤ | ទុនវិនិយោគអនុញ្ញាតដោយ ក.ក.អ. | -៨៣% | -៩២% | បើប្រៀបធៀបបីខែដើមឆ្នាំ ២០១៣ និង២០១២ លំហូទុនវិនិយោគថយចុះ៦៨% |
| ៥ | នាំចេញផលិតផលឈើកែច្នៃ | កើនយ៉ាងគំហុគ | +៨១៦% | — |



## ៧) ស្មារតេអខ្ចប្រជុំ និខការសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១២០១៣ក្នុងបីខែឆ្នាំ (នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ។ បើធៀបនឹងបីខែដូចគ្នា ឆ្នាំ២០១២ សេដ្ឋកិច្ចកម្ពុជាមានអត្រាអតិផរណាតែ ១,៥% ប៉ុណ្ណោះ។ បម្រែបម្រួលសន្ទស្សន៍ថ្លៃមានកម្រិតទាបនាដើមឆ្នាំនេះ ដោយសារថ្លៃក្រុមម្ហូបអាហារមិនសូវមានការប្រែប្រួល ថ្លៃប្រេងឥន្ធនៈមានការធ្លាក់ចុះខ្លះ ។

២ការអនុញ្ញាតឲ្យសាងសង់ក៏មានការថយចុះដែរសម្រាប់បីខែដូចគ្នា (ឆ្នាំ២០១៣ ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១២ ជាពិសេសសំណង់ធំៗ ដែលសង់ដោយក្រុមហ៊ុន។

*សេចក្តីសន្និដ្ឋាន៖*

ដោយហេតុថា វិនិយោគបរទេសជាទូទៅបម្រើឲ្យផលិតកម្មសម្រាប់នាំចេញ ដូច្នេះការនាំចូលប្រហែលជាង ៤០នៃ %តម្លៃនាំចូលសរុប គឺជាទំនិញមូលធន និងវត្ថុធាតុដើម និងប្រហែលជាង ៥០ទៀ %តជាទំនិញប្រើប្រាស់។ រីឯការនាំចេញវិញ មួយផ្នែកធំជាផលិតផលវាយនភណ្ឌ និងទំនិញកែច្នៃដ៏ទៃទៀត៩០ ប្រហែល) %) ឯការនាំចេញប្រហែល១០ទៀត ជាអង្ករ ផលិត%ផលសត្វ និងវត្ថុធាតុដើម ដូចជាកៅស៊ូ និងផលិតផលឈើ ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៤/១៣<br>ម៉ោង ០៨ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២ | ០២/០៤/១៣<br>ម៉ោង ១៥ : ២០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៣ | ០២/០៤/១៣<br>ម៉ោង ១៩ : ០០នាទី | ចូលរួមក្នុងពិធីពិសាភោជនាហារពេលល្ងាច ជាមួយអគ្គរដ្ឋទូតបារាំង នៅស្ថានទូត បារាំង។ |
| ៤ | ០៤/០៤/១៣<br>ម៉ោង ០៩ : ០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ នៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។<br>៣-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/០៤/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាង ក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ នៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៦ | ១២/០៤/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់ពហុកីឡាដ្ឋានជាតិ មរតកតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសង្កាត់ បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ |
| ៧ | ១២/០៤/១៣<br>ម៉ោង ១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧ គ.ស ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ៨ | ១៤/០៤/១៣<br>ម៉ោង ០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅមុខប្រាសាទបាយ័ន ខេត្តសៀមរាប។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ឈុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ២២/០៤/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបប ស្តីពីការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់សម្រាក គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំសមាសភាព និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាសកម្មភាពជនពិការ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ២៣/០៤/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីថ្វាយគោរម្យងារកិត្តិឧទ្ទេសបណ្ឌិត ប្រគេនសញ្ញាបត្រ កិត្តិបណ្ឌិត និងជូនគោរម្យងារកិត្តិសេដ្ឋាបណ្ឌិតនៃរាជបណ្ឌិតសភាកម្ពុជា ចំពោះមន្ត្រីសង្ឃជាន់ខ្ពស់ និងឥស្សរជនឆ្នើម នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅទីស្តីការ នាយករដ្ឋមន្ត្រី។ |
| ១១ | ២៤/០៤/១៣<br>ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ាន់ គិរុណា** និងឯកឧត្តមឧត្តមសេនីយ៍ឯក **សេខ ស៊ីណារិន** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២៥/០៤/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៣ | ២៥/០៤/១៣<br>ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនសិប្បករអង្គរ (Artisan Angkor) នៅព្រលាន យន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៤ | ២៦/០៤/១៣<br>ម៉ោង ០៨:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **អ៊ឹន ទីរជាតិ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២៦/០៤/១៣<br>ម៉ោង ១០:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ផេង សុវិជ្ជានោ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៨/០៤/១២<br>ម៉ោង ០៨:៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីសម្ពោធកុដិ និងពិធីបញ្ចុះបឋមសិលាកសាងសាលាពុទ្ធិកបឋមសិក្សា នៅវត្តវារិន្ទ ហៅវត្តព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ |
| ១៧ | ២៩/០៤/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំត្រៀមតំបន់អាស៊ីប៉ាស៊ីហ្វិក របស់អង្គការសហភាពទូរគមនាគមន៍ពិភពលោកឆ្នាំ២០១៤ (WTDC-14) ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈ រដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៤/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ២ | ០២/០៤/១៣ ម៉ោង ១៥:២០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិតសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ៣ | ០២/០៤/១៣ ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធជើងហោះហើររបស់ក្រុមហ៊ុន កម្ពុជាអ៊ែរឡាញ ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង Joint Venture ជាមួយក្រុមហ៊ុន San Miguel និង Philippine Airline និងពិធីជប់លៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| ៤ | ២៨/០៤/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចែកបណ្ណកម្មសិទ្ធិដីធ្លី ជូនប្រជាពលរដ្ឋក្នុងឃុំព្រៃអំពក ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ និងឃុំអូរសារាយ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅភូមិឈើទាលភ្លោះ ឃុំព្រៃអំពក ស្រុកគីរីវង់ ខេត្តតាកែវ។ |
| ៥ | ២៩/០៤/១៣ ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំត្រៀមតំបន់អាស៊ីប៉ាស៊ីហ្វិក របស់អង្គការសហភាពទូរគមនាគមន៍ពិភពលោក ឆ្នាំ២០១៤ (WTDC-14) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៤/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ២ | ០២/០៤/១៣ ម៉ោង ១៥:២០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិតសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ៣ | ២៨/០៤/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចែកបណ្ណកម្មសិទ្ធិដីធ្លី ជូនប្រជាពលរដ្ឋក្នុងឃុំព្រៃអំពក ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ និងឃុំអូរសារាយ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅភូមិឈើទាលភ្លោះ ឃុំព្រៃអំពក ស្រុកគីរីវង់ ខេត្តតាកែវ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៣

## ឯកឧត្តម ច៉ាន់ និរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៤/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២ | ០២/០៤/១៣<br>ម៉ោង ១៥:២០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិតសន្និបាតជាតិ វិស័យសកម្មភាពមីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៣ | ០២/០៤/១៣<br>ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធជើងហោះហើររបស់ក្រុមហ៊ុន កម្ពុជាអ៊ែរឡាញ ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង Joint Venture ជាមួយក្រុមហ៊ុន San Miguel និង Philippine Airline និងពិធីជប់លៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| ៤ | ០៥/០៤/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើ របៀបវារៈដូចខាងក្រោមៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៥ | ២៩/០៤/១៣<br>ម៉ោង ០៩:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំត្រៀមតំបន់អាស៊ីប៉ាស៊ីហ្វិក របស់អង្គការសហភាពទូរគមនាគមន៍ពិភពលោក ឆ្នាំ២០១៤ (WTDC-14) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |